# ខ្លឹមសារសង្ខេប
# ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ( UNHRC )
# បណ្ដឹងលេខ ១៨១៥/២០០៨

**១.ពាក្យគន្លឹះ៖** សិទ្ធិជំនួយផ្លូវច្បាប់ (មេធាវី), បរិហារកេរ និងសេរីភាពសំដែងមតិ។

**២. នីតិវិធី៖** អ្នកប្ដឹងមានឈ្មោះ Adonis ជាជនជាតិហ្វីលីពីន ធ្វើការងារក្នុងក្រុមហ៊ុនផ្សាយព័ត៌មាន (radio) បានរាយការណ៍អំពីរឿងអាស្រូវផ្លូវភេទរបស់តំណាងរាស្ត្រ។ មានការចោទប្រកាន់ពីបទបរិហារកេរ លើប្រធានក្រុមហ៊ុននេះ ក៏ប៉ុន្តែត្រូវបានបដិសេធ ដោយសារគ្មានភស្តុតាងគ្រប់គ្រាន់។ ទោះបីជាយ៉ាងនេះក្ដី អ្នកប្ដឹងត្រូវបានចោទ ហើយផ្ដន្ទាទោស ជាងបួនឆ្នាំដាក់ពន្ធនាគារពីបទបរិហារកេរ។ ដោយសារ ការកាត់ទោសនេះ គាត់មានជំងឺធ្លាក់ទឹកចិត្ត។ គាត់មិនមានមេធាវីទេ នាពេលក្រោយមក ខណៈព័ត៌មានស្ដីពីការដកខ្លួនរបស់មេធាវី មិនត្រូវបានផ្ដល់ជូនគាត់ ហើយសវនាការ ត្រូវបានធ្វើឡើងដោយកំបាំងមុខ (*in absentia*)។ បន្ថែមពីលើនេះ គាត់ខកខានមិនបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រម។ ច្បាប់របស់ហ្វីលីពីន មិនអនុញ្ញាត ឲ្យយក «ការពិត ឬ ការបោះពុម្ពសមហេតុផល» (defence of truth or reasonable publication) ជាការដោះសារឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ គាត់អះអាងថា អង្គហេតុនេះ បំពានមាត្រា១ (៣.ឃ) ហើយ ការដាក់ទោសព្រហ្មទណ្ឌ លើបទបរិហារកេរនេះ ជាការកម្រិតសេរីភាព ដែលផ្ទុយនឹងមាត្រា១៩ នៃកតិកាសញ្ញា។ គាត់ ទាមទារឲ្យមានការដោះលែង និង សំណងដោយហ្វីលីពីន ចំពោះការបំពានសិទ្ធិទាំងនេះ។

រដ្ឋភាគី បានតបថាសិទ្ធិសេរីភាពសំដែងមតិមិនដាច់ខាតទេ។ ការរិះគន់ គឺត្រូវទៅលើគោលនយោបាយ មិនមែនលើជីវិតឯកជនគេទេ។ ពាក់ព័ន្ធនឹងការទទួលបានមេធាវី ច្បាប់ប្រទេសហ្វីលីពីន ទទួលស្គាល់សិទ្ធិមានជំនួយផ្លូវច្បាប់ (កថាខ័ណ្ឌទី៤.៣)។

## ៣. សំអាងហេតុ និងសេចក្ដីសម្រេច

**ក.** ឯកសារតុលាការ តាមច្បាប់របស់ប្រទេសហ្វីលីពីន ត្រូវបានផ្ដល់ជូនមេធាវីតំណាងឲ្យជនជាប់ចោទ។ ក្នុងពេលមានការដកខ្លួនរបស់មេធាវី ជនជាប់ចោទមិនត្រូវបានផ្ដល់ដំណឹងទេ។ បន្ថែមពីលើនេះ ជនជាប់ចោទមិនបានដឹងអំពីការបន្តនីតិវិធីប្រឆាំងនឹងគាត់ ខណៈគាត់នៅឆ្ងាយ នាំឲ្យសវនាការគាត់កំបាំងមុខ។ អង្គហេតុនេះ មិនត្រូវបានជំទាស់ដោយរដ្ឋភាគីទេ ហើយរដ្ឋភាគី មិនបានផ្ដល់ភស្តុតាងថា ជនជាប់ចោទ ត្រូវបានជូនដំណឹងសមស្រប ពីការដកខ្លួនរបស់មេធាវី និង ប្រាប់ក្នុងពេលសមស្រប នូវសេចក្ដី

សម្រេចអនុញ្ញាតឲ្យប្ដឹងឧទ្ធរណ៍ផងដែរ។ អង្គហេតុនេះ នាំឲ្យមានការបំពានមាត្រា ១៤ (៣.ឃ) នៃកតិកាសញ្ញា (កថាខ័ណ្ឌទី៧.៦)។

**ខ**. គណៈកម្មាធិការកត់សំគាល់ថា តាមយោបល់ទូទៅលេខ ៣៤ ច្បាប់ស្ដីពីបរិហារកេរ ត្រូវធានាអនុលោមភាពតាមកថាខ័ណ្ឌទី៣នៃមាត្រា១៩។ ក្នុងករណី ជាបទព្រហ្មទណ្ឌ ការដោះសារថា ជាខ្លឹមសារពិត (defence of truth) គួរត្រូវបញ្ចូល ហើយច្បាប់មិនគួរអនុវត្តចំពោះទម្រង់នៃការសំដែងមតិដែលមិនអាចផ្ទៀងផ្ទាត់បាននោះទេ។ ការរិះគន់លើមន្ត្រីសាធារណៈ មិនគួរមានទោសព្រហ្មទណ្ឌ។ ផលប្រយោជន៍សាធារណៈ (public interest) ក៏គួរជាការដោះសារផងដែរ។ វិធានការដាក់ទោស ក៏គួរកុំធ្ងន់ធ្ងរពេក...រដ្ឋគួរដកបទបរិហារកេរ ចេញពីបទល្មើសព្រហ្មទណ្ឌ។ ផ្ទុយពីនេះ គណៈកម្មាធិការ រកឃើញថា ច្បាប់ហ្វីលីពីនមិនបាន ផ្ដល់នូវការដោះសារ និង សន្មតថាមានចេតនាទុច្ចរិត (malice) និងតម្រូវឲ្យជនជាប់ចោទផ្ដល់ភស្តុតាងបដិសេធ (បន្ទុកភស្តុតាង) នូវចេតនាទុច្ចរិតនេះ។ គណៈកម្មាធិការ រកឃើញថា មានការបំពានមាត្រា ១៩(៣) នៃកតិកាសញ្ញា (កថាខ័ណ្ឌទី៧.១០)។

### ៤. កំណត់សំគាល់ (ខ្លឹមសារល្អ សម្រាប់ដកស្រង់)

*បទល្មើសបរិហារកេរ វាមិនមែនជាការកម្រិតមានយុត្តិកម្មទេ លើសេរីភាពសំដែងមតិទេ ច្បាប់ដាក់បទបរិហារកេរជាបទល្មើស គួរត្រូវលុប ឬនិរាករណ៍ចោល ជំនួសដោយច្បាប់បរិហារកេរមិនមែនចាត់ជាបទព្រហ្មទណ្ឌ* (civil defamation law) *ប្រសិនបើចាំបាច់* (កថាខ័ណ្ឌទី៣.១)។

*គណៈកម្មាធិការ សូមរំលឹកយុត្តិសាស្ត្ររបស់ខ្លួនថា នីតិវិធី ដោយគ្មានវត្តមានរបស់ជនជាប់ចោទក្នុងកាលៈទេសៈ អាចត្រូវបានអនុញ្ញាត ក្នុងផលប្រយោជន៍នៃរដ្ឋបាលសមស្រប នៃយុត្តិធម៌ ទោះបីជាមានការជូនដំណឹងអំពីនីតិវិធីគ្រប់គ្រាន់ជាមុនក្ដី បដិសេធមិនប្រាស្រ័យសិទ្ធិមានវត្តមាន។ ជាលទ្ធផល សវនាការទាំងនោះ នឹងស្របតាមមាត្រា ១៤(៣.ឃ) ប្រសិនបើវិធានការចាំបាច់ ត្រូវបានប្រកាន់យកដើម្បីកោះហៅ ជនជាប់ចោទ ទាន់ពេលវេលា និងជូនដំណឹង ពួកគេជាមុនអំពីកាលបរិច្ឆេទ ព្រមទាំងទីកន្លែង នៃសវនាការ និងស្នើឲ្យមានការចូលរួម* (កថាខ័ណ្ឌទី៧.៤)។

ទស្សនៈទាំងស្រុងសូមមើល៖ CCPR/C/103/D/1815/2008/Rev.1, Communication No. 1815/2008, Alexander Adonis v. the Philippines